ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋាន រតនាគារជាតិ
លេខ :...៩៨៣៨...អ.រតជ.

ថ្ងៃ អង្គារ ១៣រោច ខែ អាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២២

## សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ចំនួន ២រូប ដើម្បីបម្រើការងារ នៅអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានរតនាគារជាតិ សូមជម្រាបជូនដល់សាធារណៈជនជ្រាបថា÷ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវការជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យា ចំនួន ២រូប សម្រាប់បំពេញការងារពេញម៉ោង ដូចខាងក្រោម÷

១. ភារកិច្ចនិងការទទួលខុសត្រូវ÷

- ជួយការងារក្នុងនាយកដ្ឋានគោលការណ៍គណនេយ្យនិងវិភាគការអនុវត្តថវិកា
- ចូលរួមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានរតនាគារជាតិ
- បកប្រែឯកសារពីភាសាបរទេសមកភាសាខ្មែរ ឬ ពីភាសាខ្មែរទៅភាសាបរទេស (បារាំង ឬ អង់គ្លេស)
- រៀបចំកំណត់ហេតុ និងរបាយការណ៍ប្រជុំនានា
- ចូលរួមនិងរៀបចំវគ្គបណ្តុះបណ្តាលជំនាញពាក់ព័ន្ធ
- ចូលរួមសម្របសម្រួលការងារជាមួយក្រុមបេសកកម្មជំនាញការបារាំង
- ត្រៀមលក្ខណៈសម្រាប់ទទួលការបណ្តុះបណ្តាលជំនាញគណនេយ្យសាធារណៈ នៅសាធារណរដ្ឋបារាំង
- ចូលរួមកិច្ចប្រជុំពិភាក្សាការងារផ្សេងៗ និង
- បំពេញការងារផ្សេងទៀតតាមការប្រគល់ជូនពីអ្នកគ្រប់គ្រង។

២. គុណវុឌ្ឍិ÷

បេក្ខជន ឬ បេក្ខនារី ត្រូវមាន÷

- សញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើងទៅ លើជំនាញ គណនេយ្យ ឬ ហិរញ្ញវត្ថុ
- បទពិសោធន៍ការងារក្នុងវិស័យគណនេយ្យ ឬ ហិរញ្ញវត្ថុ ចាប់ពី១ឆ្នាំឡើង
- ចំណេះដឹងច្បាស់លាស់ផ្នែកភាសាបារាំង
- ចំណេះដឹងច្បាស់លាស់ក្នុងការប្រើប្រាស់កម្មវិធី Ms. Office
- សមត្ថភាពរៀបចំនិងធ្វើបទបង្ហាញអំពីលទ្ធផលការងារ
- ភាពអត់ធ្មត់ តស៊ូ ច្នៃប្រឌិត បុរេសកម្មលើការងារ និងឆន្ទៈខ្ពស់ក្នុងការបំពេញការងារ



អាគារលេខ ១៩ វិថី ព្រះមហាក្សត្រីយានីកុសមៈ (ផ្លូវលេខ ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ : ០២៣ ៧២២ ៨១៦

- សមត្ថភាពបំពេញការងារដោយឯករាជ្យ និងជាក្រុម។

បេក្ខជន ឬ បេក្ខនារីដែលនឹងត្រូវបានជ្រើសរើស នឹងមានឱកាសទៅរៀននៅសាលាជាតិហិរញ្ញវត្ថុសាធារណៈនៃសាធារណរដ្ឋបារាំង និងអាចក្លាយជាមន្ត្រីរាជការក្នុងក្របខណ្ឌមុខងារសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយពីទទួលបានការវាយតម្លៃសមិទ្ធផលការងារ និងបានបម្រើការងារក្នុងរយៈពេលកំណត់មួយ។

បេក្ខជន ឬ បេក្ខនារី ដែលមានចំណាប់អារម្មណ៍ និងមានគុណវុឌ្ឍិ ដូចបានរៀបរាប់ខាងលើ សូមផ្ញើប្រវត្តិរូបសង្ខេប (CV) និងលិខិតចំណាប់អារម្មណ៍ការងារ (Cover Letter) ជាភាសាខ្មែរ មកកាន់អគ្គនាយកដ្ឋានរតនាគារជាតិ អគារលេខ ១៩ រុក្ខវិថីព្រះមហាក្សត្រីយានីកុសមៈ (ផ្លូវលេខ ១៩) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ រៀងរាល់ម៉ោងធ្វើការ ឬ តាមរយៈអ៊ីម៉ែល suos.sereyrortha@gmail.com។ កាលបរិច្ឆេទឈប់ទទួលពាក្យ **ត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៧:៣០នាទី**។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង **លោកស្រី សួស សិរីរដ្ឋា** តាមរយៈលេខទូរស័ព្ទនិងតេលេក្រាម **០៧៧ ៣៦០ ២២៣**។

សម្គាល់÷ មានតែបេក្ខជន ឬ បេក្ខនារីដែលជាប់ដំណាក់កាលសម្រាំងជ្រើសរើសដំបូង (Shortlist) តែប៉ុណ្ណោះ ដែលនឹងត្រូវអញ្ជើញមកធ្វើតេស្ត និងសម្ភាសន៍ផ្ទាល់មាត់។

**អគ្គនាយកដ្ឋានរតនាគារជាតិ**